**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧៥/០១៩/២០០៣

ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ : ០៥៨/០០៩/២០០៣ កបធ.ច

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ៤២៧ រស ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា បញ្ជូនលិខិតលោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (COMFREL) មកក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យធ្វើការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាមពាក្យបណ្តឹងលេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃ ទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០៣ ។

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាផ្ទឹមផ្ទៀងតាមច្បាប់ហើយ**

-យល់ឃើញថា តាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យពិភាក្សាបាន

-យល់ឃើញថា មាត្រា ៧៦ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឱ្យច្បាប់បោះឆ្នោតកំណត់អំពី "អង្គការរៀបចំការបោះឆ្នោត របៀបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត "

-យល់ឃើញថា តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្តីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គំនិតគឺឱ្យ គជប ជាអ្នកធ្វើការពិន័យ

-យល់ឃើញថា តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភានាឆ្នាំ ២០០២ និង ឆ្នាំ ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្តីព្រាងមាត្រា ១២៤ ថ្មី និង មាត្រា ១២៤ ចាស់ លើចំណុចខាងលើនេះទេ

-យល់ឃើញថា មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត..." ។ ក្នុងឃ្លានេះ យោងតាមទឡ្ហីករណ៍ខាងលើ ការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គជប ដែរ ។

**សំរេច**

**មាត្រា ១.-** មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៣

ប៊ិន ឈិន